**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**និយ័តករទូរគមនាគមន៍កម្ពុជា**

នាយកដ្ឋានការប្រកួតប្រជែង
និងការការពារអ្នកប្រើប្រាស់
លេខ.០០៩៦.ន.ប្រ.ក.ប្រ

**សូមគោរពជូន**

**ឯកឧត្តមប្រធាននិយ័តករទូរគមនាគមន៍កម្ពុជា**

**តាមរយៈ** ៖ ឯកឧត្តមសមាជិកទទួលបន្ទុកនាយកដ្ឋាន ន.ប្រ.ក.ប្រ.

**កម្មវត្ថុ** ៖ សំណើសុំពិនិត្យលើ "ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម" (Application Form For Promotion) និងសម្រេចដាក់ចូលក្នុងគេហទំព័ររបស់ ន.ទ.ក. សំរាប់ប្រើប្រាស់ជាផ្លូវការ។

**យោង** ៖- កំណត់ហេតុប្រជុំផ្ទៃក្នុង នាថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៨ របស់នាយកដ្ឋានការប្រកួតប្រជែង និងការការពារអ្នកប្រើប្រាស់។

- កំណត់ហេតុប្រជុំ នាថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៨ ក្រោមការដឹកនាំរបស់ **ឯកឧត្តម ស៊ា ណារ៉េត** សមាជិកនិយ័តករទូរគមនាគមន៍កម្ពុជា ។

សេចក្តីដូចបានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយស សូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ដើម្បីងាយស្រួលលើការគ្រប់គ្រងសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្មរបស់ប្រតិបត្តិករទូរគមនាគមន៍ នាយកដ្ឋានជំនាញបានយកចិត្តទុកដាក់ស្រាវជ្រាវនិងរៀបចំជា "ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម" សម្រាប់ដាក់លើគេហទំព័ររបស់ ន.ទ.ក. ជូនប្រតិបត្តិករប្រើប្រាស់ជាផ្លូវការ។ នៅថ្ងៃទី ២១ ខែមីនា ឆ្នាំ២០១៨ វេលាម៉ោង ០៨ព្រឹក ន.ប្រ.ក.ប្រ. បានប្រជុំពិភាក្សាផ្ទៃក្នុងដើម្បីកែសម្រួលលើ "ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម" នេះ។ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៨ វេលាម៉ោង ០៤រសៀល នៅបន្ទប់សាលប្រជុំតូច ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ស៊ា ណារ៉េត** បានពិភាក្សានិងកែសម្រួលសំរេចលើ "ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម" នេះម្តងទៀត ។

សូមជូនភ្ជាប់មកជាមួយ៖ សេចក្តីព្រាង "ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម" របស់ប្រតិបត្តិករទូរគមនាគមន៍ ចំនួន០១ច្បាប់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសំរេចអោយដាក់ "ពាក្យស្នើសុំធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម"ក្នុងគេហទំព័ររបស់ ន.ទ.ក. បានប្រើប្រាស់ជាផ្លូវការ ដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៨

**ប្រធាននាយកដ្ឋាន**

ស្បៀង_សិទ្ធី

បានឃើញ និងសូមគោរពជូន

**ឯកឧត្តមប្រធាន**

មេត្តាជ្រាប និងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១៨

**សមាជិក**

ស៊ា ណារ៉េត